ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
* * * * * *

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
* * * * * *

## ឯកឧត្តម ប្រាក់ សុខុន ៖ អាទិភាពសំខាន់របស់កម្ពុជា គឺការរក្សាឲ្យបាននូវសន្តិភាព ស្ថេរភាព ដែលជាលក្ខខ័ណ្ឌចម្បង និងចាំបាច់មិនអាចខ្វះបាន សំរាប់ការអភិវឌ្ឍសេដ្ឋកិច្ច ក៏ដូចជាការពង្រឹង លទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស

* * * * * *

ក្នុងជំនួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅព្រឹកថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨ របស់ឯកឧត្តម Kentaro Sonoura ទីប្រឹក្សារបស់នាយករដ្ឋមន្រ្តីជប៉ុន ឯកឧត្តមទេសរដ្ឋមន្រ្តី **ប្រាក់ សុខុន** រដ្ឋមន្រ្តីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានសម្តែងការស្វាគមន៍យ៉ាងកក់ក្តៅចំពោះដំណើរទស្សនកិច្ចរបស់**ឯកឧត្តមទីប្រឹក្សា** ហើយបានរំលឹកអំពីជំនួបថ្មីៗនេះ រវាង**ឯកឧត្តម**ផ្ទាល់ ជាមួយឯកឧត្តម Kazuyuki Nakane អនុរដ្ឋមន្រ្តីការបរទេសជប៉ុន ក្នុងឱកាសទស្សនកិច្ចការងារថ្ងៃទី២៨-២៩ ខែមករាកន្លងមកនេះ ដែលការពិភាក្សាបានផ្តោតជាសំខាន់ទៅលើការពង្រឹង និងពង្រីកបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យរវាងប្រទេសទាំងពីរ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានសម្តែងនូវអំណរគុណដ៏ជ្រាលជ្រៅរបស់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា សម្រាប់ជំនួយឧបត្ថម្ភដ៏ថ្លៃថ្លារបស់ជប៉ុន ចំពោះដំណើរការសន្តិភាព ក៏ដូចជាដំណើរការស្តារ និងកសាងកម្ពុជាឡើងវិញ ហើយបានគូសបញ្ជាក់ថាជំនួយរបស់ជប៉ុនបានរួមចំណែកយ៉ាងសំខាន់ក្នុងកិច្ចអភិវឌ្ឍកម្ពុជា។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានជំរាបអំពីការត្រៀមលក្ខណៈរបស់ឯកឧត្តម និងក្រសួងការបរទេស ក្នុងការទទួលដំណើរទស្សនកិច្ចផ្លូវការរបស់ឯកឧត្តម Taro Kono រដ្ឋមន្រ្តីការបរទេសជប៉ុន មកកាន់កម្ពុជា ក្នុងខែមេសាខាងមុខនេះ ដែលនឹងជាការរួមចំណែកដ៏សំខាន់មួយទៀតក្នុងការលើកស្ទួយទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការជាដៃគូយុទ្ធសាស្រ្តកម្ពុជា-ជប៉ុន។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានសំដែងការរីករាយពេញចិត្តចំពោះការវិវឌ្ឍដ៏ល្អប្រសើរក្នុងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី តំបន់ និងពហុភាគី ហើយបានសំដែងជំនឿជាក់ថាកិច្ចសហប្រតិបត្តិការនេះ នឹងត្រូវបានពង្រឹងបន្ថែមទៀតក្នុងឆ្នាំ២០១៨នេះ ដែលជាឆ្នាំប្រារព្ធខួបលើកទី៦៥ នៃទំនាក់ទំនងការទូតកម្ពុជា-ជប៉ុន។

**ឯកឧត្តមទីប្រឹក្សា** បានជម្រាបជូន**ឯកឧត្តមទេសរដ្ឋមន្ត្រី** អំពីការយកចិត្តទុកដាក់របស់រដ្ឋាភិបាលជប៉ុនចំពោះទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យជាមួយកម្ពុជា ហើយ**ឯកឧត្តម** បានសម្តែងក្តីរីករាយចំពោះការត្រៀមលក្ខណៈរបស់ប្រទេសទាំងពីរ ក្នុងការប្រារព្ធខួបលើកទី៦៥ នៃទំនាក់ទំនងការទូត ក៏ដូចជាការត្រៀមរៀបចំសម្រាប់ដំណើរទស្សនកិច្ចរបស់**ឯកឧត្តមរដ្ឋមន្ត្រីការបរទេសជប៉ុន** មកកាន់កម្ពុជា។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានវាយតំលៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរលើផ្នែកការពារប្រទេស ពិសេសការជួយរបស់ជប៉ុនក្នុងការកសាងសមត្ថភាពកងកំលាំងមួកខៀវកម្ពុជាដើម្បីចូលរួមក្នុងបេសកកម្មរក្សាសន្តិភាពក្រោមឆ័ត្រអ.ស.ប ហើយនិងការបោសសំអាតមីន និងកាកសំណល់យុទ្ធភ័ណ្ឌសង្គ្រាម នៅកម្ពុជា។

**ឯកឧត្តមទីប្រឹក្សា** បានវាយតំលៃខ្ពស់ចំពោះការចូលរួមយ៉ាងសកម្មរបស់កម្ពុជាក្នុងបេសកកម្មរក្សាសន្តិភាពរបស់អ.ស.ប និងការបន្តកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរលើផ្នែកនេះ។ **ឯកឧត្តមទីប្រឹក្សា** បានគូសបញ្ជាក់ថា រដ្ឋាភិបាលជប៉ុនកំពុងពិចារណាយ៉ាងយកចិត្តទុកដាក់ និងពិនិត្យលទ្ធភាពក្នុងការផ្តល់ការគាំទ្រដល់មជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីន (ARMAC) តាមសំណូមពររបស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** និងរបស់**ឯកឧត្តមទេសរដ្ឋមន្ត្រី**។

នៅក្នុងជំនួបនេះ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានធ្វើការបកស្រាយលំអិតជំរាប**ឯកឧត្តមទីប្រឹក្សា** អំពីសភាពការណ៍បច្ចុប្បន្ននៅកម្ពុជា និងបានគូសបញ្ជាក់ច្បាស់ថាការចាត់វិធានការរបស់ស្ថាប័ននីតិប្បញ្ញត្តិ ប្រតិបត្តិ និងតុលាការកន្លងមក គឺផ្អែកលើអង្គហេតុច្បាស់លាស់ និងច្បាប់ជាធរមាននានារបស់កម្ពុជា ក្នុងគោលដៅទប់ស្កាត់ការប៉ុនប៉ងផ្តួលរំលំរដ្ឋាភិបាលស្របច្បាប់នៅកម្ពុជាតាមវិធីមិនប្រជាធិបតេយ្យ ពង្រឹងនីតិរដ្ឋ ការពារឯករាជ្យ និងអធិបតេយ្យ ប្រឆាំងការជ្រៀតជ្រែករបស់បរទេសចូលកិច្ចការផ្ទៃក្នុងកម្ពុជា ហើយនិងដើម្បីរក្សាសន្តិភាព ស្ថិរភាព ដែលកម្ពុជាទទួលបានដោយការតស៊ូដ៏លំបាកវេទនាខ្លាំងក្លាបំផុត។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា កន្លងមកកម្ពុជាបានផ្តល់នូវការបកស្រាយយ៉ាងច្បាស់លាស់អំពីបញ្ហាទាំងអស់នេះ ជូនទៅសហគមន៍អន្តរជាតិ តែអ្វីដែលជាការលំបាកសម្រាប់កម្ពុជាដែលជាប្រទេសតូចមួយ គឺលទ្ធភាពនៃការយកឈ្នះទៅលើឥទ្ធិពលនៃក្បាលម៉ាស៊ីនឃោសនាដ៏ខ្លាំងក្លាដែលនៅពីក្រោយយុទ្ធនាការប្រឆាំងកម្ពុជា តាមរយៈការឃោសនាផ្សព្វផ្សាយព័ត៌មានមិនពិតអំពីកម្ពុជា ដែលការឃោសនានេះ បានជះឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំង និងបានបង្កការយល់ខុសឆ្គងចំពោះសភាពការណ៍ជាក់ស្តែងនៅកម្ពុជា។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានឆ្លៀតឱកាសនេះ សំដែងអំណរគុណចំពោះរដ្ឋាភិបាលជប៉ុន ដែលបានជួយការពារយុត្តិធម៌សំរាប់កម្ពុជា និងបានសំដែងជំហរប្រកបដោយការថ្លឹងថ្លែងចំពោះសភាពការណ៍កម្ពុជា ពិសេសនៅក្នុងកិច្ចប្រជុំនានាស្តីពីសិទ្ធិមនុស្ស នៅទីក្រុងហ្សឺណែវកន្លងមក។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានជំរាបជូន**ឯកឧត្តមទីប្រឹក្សា** អំពីអាទិភាពសំខាន់របស់កម្ពុជានៅពេលនេះ គឺត្រូវរក្សាឲ្យបាននូវសន្តិភាព ស្ថេរភាព ដែលជាលក្ខខ័ណ្ឌចម្បង និងចាំបាច់មិនអាចខ្វះបាន សំរាប់ការអភិវឌ្ឍសេដ្ឋកិច្ច ក៏ដូចជាការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស។

**ឯកឧត្តមទីប្រឹក្សា** បានសំដែងអំណរគុណចំពោះការបំភ្លឺរបស់**ឯកឧត្តមទេសរដ្ឋមន្ត្រី** និងបានគូសបញ្ជាក់អំពីជំហររបស់រដ្ឋាភិបាលជប៉ុន គោរពកិច្ចការផ្ទៃក្នុង និងច្បាប់របស់កម្ពុជា ចង់ឃើញកម្ពុជាមានទំនាក់ទំនងល្អជាមួយសហគមន៍អន្តរជាតិ ហើយទន្ទឹមនឹងនោះ ចង់ឃើញកម្ពុជារក្សាបាននូវសន្តិភាព ស្ថេរភាព និងការអភិវឌ្ឍដែលកម្ពុជារក្សាបានរហូតមកដល់ពេលបច្ចុប្បន្ននេះ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** និង**ឯកឧត្តមទីប្រឹក្សា** ក៏បានពិភាក្សាផ្លាស់ប្តូរយោបល់គ្នាផងដែរអំពីការពង្រឹងកិច្ចសហប្រតិបត្តិការកម្ពុជា-ជប៉ុន ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការមេគង្គ-ជប៉ុន ហើយនិងគំនិតផ្តួចផ្តើមរបស់ជប៉ុន និងរបស់ប្រទេសផ្សេងៗទៀតស្តីពី "ឥណ្ឌូ-ប៉ាស៊ីហ្វិក"។

ជំនួបនេះ បានបញ្ចប់ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាល។

ថ្ងៃ អាទិត្យ ៩កើត កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ភ្នំពេញ, ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០១៨